## ព្រះរាជក្រឹត្យនេះ — ត្រាស់បង្គាប់

**មាត្រា ១.-** តែងតាំងឯកឧត្តម **ឈី គឹមហាន** ជាសមាជិកព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា សំរាប់នីតិកាលទី១ ជំនួស ឯកឧត្តម **ស៊ិន សុខ** ដែលបានទទួលមរណៈភាព ។

**មាត្រា ២.-** ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ . ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០០១

ក្នុងព្រះបរមនាម និង តាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

**ជា ស៊ីម**

# II- រាជរដ្ឋាភិបាល

## អនុក្រឹត្យ

## អនុក្រឹត្យលេខ ២៨ អនក្រ.បក

## កែសំរួលនិងបំពេញបន្ថែមអនុក្រឹត្យលេខ ០៥ អនក្រ.បក ស្តីពីការបង្កើតគណៈកម្មាធិការអន្តរក្រសួងសំរបសំរួលការត្រួតពិនិត្យគុណភាព សុវត្ថិភាពផលិតផល និងសេវាកម្ម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការគ្រប់គ្រង គុណភាព សុវត្ថិភាព លើផលិតផលទំនិញ និង សេវា
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតគណៈកម្មាធិការអន្តរក្រសួង សំរបសំរួលការត្រួតពិនិត្យគុណភាព សុវត្ថិភាពផលិតផល និងសេវាកម្ម
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សំរេច**

**មាត្រា ១ .-**

មាត្រា ៤ នៃអនុក្រឹត្យលេខ ០៥ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតគណៈកម្មាធិការអន្តរក្រសួងសំរបសំរួលការត្រួតពិនិត្យគុណភាព សុវត្ថិភាពផលិតផល និងសេវាកម្មត្រូវបានកែសំរួល និងបំពេញបន្ថែមដូចខាងក្រោម :

**មាត្រា ៤ ថ្មី**

ក-គណកម្មាធិការមានភារកិច្ចរៀបចំដាក់ជូនរដ្ឋមន្ត្រី នៃក្រសួងជាសមាជិកពិនិត្យនូវ :

-សេចក្តីព្រាងសំរាប់ធ្វើអោយបានប្រសើរ នូវការបែងចែកភារកិច្ចរវាងបណ្តាក្រសួងក្នុងវិស័យកំណត់ខាងលើ នូវកិច្ចសំរបសំរួលនៃសកម្មភាពនានារបស់បណ្តានាយកដ្ឋាន និងនូវស្ថាប័នត្រួតពិនិត្យ ។

-សំណើអំពីនយោបាយជាតិ ស្តីពីគុណភាព និងសុវត្ថិភាពនៃផលិតផល និងសេវា កិច្ចការពារអ្នកប្រើ និងភាពស្មោះត្រង់នៃកិច្ចការជំនួញ ស្របតាមច្បាប់ ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផល ទំនិញ និងសេវា ។

ក្នុងក្របខ័ណ្ឌនៃភារកិច្ចទាំងពីរខាងលើ គណកម្មាធិការមានកិច្ចការជាក់ស្តែងដូចតទៅ :

-ទទួលទៀងទាត់តាមពេលកំណត់នូវរបាយការណ៍សកម្មភាពរបស់ស្ថាប័ន និងនាយកដ្ឋានពាក់ព័ន្ធនិមួយៗ និងផ្តល់ការណែនាំសំរាប់ធ្វើអោយបានប្រសើរ នូវប្រព័ន្ធជាតិនៃកិច្ចការត្រួតពិនិត្យ ។

-ទទួលនូវគំរោងការងារដែលបណ្តាស្ថាប័ន និងនាយកដ្ឋាននានាបានតាក់តែងកសាង ក្នុងវិស័យផ្ទាល់របស់គេ និងលើកសំណើទាំងអស់អំពីការអនុវត្តណ៍តាមគោលការណ៍ឯកភាព ឬ អំពីការសំរបសំរួល នៃសកម្មភាពទាំងឡាយនោះ ។

-លើកសំណើ និងសំរបសំរួលប្រតិបត្តិការត្រួតពិនិត្យជាពិសេសលើបណ្តាបញ្ហា ដែលត្រូវបានប្រកាសជាអាទិភាព ហើយដែលទាក់ទងទៅនឹងស្ថាប័ន ឬ នាយកដ្ឋានពាក់ព័ន្ធទាំងអស់ ឬណាមួយ ។

-តាក់តែងកសាងកម្មវិធីនៃកិច្ចយកគំរូ ដែលអនុគ្រោះអោយរៀបចំបានល្អប្រសើរ នូវដំណើរការនៃបណ្តាមន្ទីរពិសោធណ៏វិភាគ និងសាកល្បង ។

-ទទួលបន្ទុកនូវការផ្តើមបង្កើតអោយមាន និងនូវដំណើរការនៃប្រព័ន្ធផ្តល់ដំណឹងពីភាពអាសន្នក្នុងករណីមានគ្រោះអាសន្នធ្ងន់ធ្ងរចំពោះសុខភាព និងសុវត្ថិភាពអ្នកប្រើ ។

-លើកសំណើគំនិតសំរាប់ជាអាជ្ញាកណ្តាល ក្នុងករណីមានជម្លោះសមត្ថកិច្ច ដែលមានកើតឡើងរវាងក្រសួងផ្សេងៗ ។

-កសាងរៀងរាល់ឆ្នាំនូវរបាយការណ៍មួយស្តីពីសកម្មភាពរបស់ខ្លួន ដែលមានបញ្ជាក់ជាអាទិ៍នូវគុណ្យការនៃសកម្មភាពរយៈពេលកន្លងទៅ នូវគំរោងសំរាប់ឆ្នាំខាងមុខ និងរាល់សំណើមានប្រយោជណ៏ ។

-ត្រូវបានគេពិគ្រោះយោបល់ លើគ្រប់សំណើព្រាងលិខិតបទដ្ឋានសំដៅរៀបចំអោយបានត្រឹមត្រូវតាមកាលៈទេសជាក់ស្តែង ឬ បំពេញបង្គ្រប់នូវបទប្បញ្ញត្តិដែលមានស្រាប់ ។

ខ-គណៈកម្មាធិការទទួលនាទីជាគណកម្មាធិការ Codex ជាតិ សំរាប់បំពេញរាល់កិច្ចការពាក់ព័ន្ធនឹងបច្ចេកទេស និងគោលនយោបាយនៃបទដ្ឋានអន្តរជាតិរបស់ផលិតផលចំណីអាហារ ដោយមានភារកិច្ចលំអិតដូចខាងក្រោម :

-តែងតាំងអនុគណៈកម្មការជំនាញមួយចំនួនតាមការចាំបាច់សំរាប់ជាជំនួយការ ក្នុងការសិក្សា ឬពិចារណាលើបញ្ហាបច្ចេកទេស ។

-សិក្សាឯកសារ Codex ប្រមូល និងពិនិត្យពិចារណារាល់ពត៌មាន ដែលមានខ្លឹមសារទាក់ទងទៅនឹងបច្ចេកវិទ្យា [illegible] សុវត្ថិភាព ប្រព័ន្ធត្រួតពិនិត្យសំរាប់មានលទ្ធភាពផ្តល់នូវហេតុផលជាមូលដ្ឋានគាំទ្រក្នុងការទទួលយកស្តង់ដា Codex ។

-ស្នើទៅរាជរដ្ឋាភិបាលនូវវិធីនៃការទទួលយកស្តង់ដាអន្តរជាតិនៃផលិតផលចំណីអាហារ និង ស្នើទៅរាជរដ្ឋាភិបាលនូវបណ្តាស្ថាប័នដែលទទួលបន្ទុកអនុវត្ត ។

-សហប្រតិបត្តិការជាមួយកម្មវិធីស្តង់ដាចំណីអាហាររួមគ្នារវាងអង្គការ FAO និងអង្គការ WHO និងចាត់តាំងគណប្រតិភូចូលរួមក្នុងកិច្ចប្រជុំនានារបស់ Codex .

-សហប្រតិបត្តិការជាមួយបណ្តាអង្គការក្នុងស្រុក និងអន្តរជាតិផ្សេងទៀត ដែលមានភារកិច្ច ពាក់ព័ន្ធជាមួយនឹងបទដ្ឋានផលិតផលចំណីអាហារ ។

-កិច្ចការទាំងឡាយផ្សេងទៀត ដែលពាក់ព័ន្ធនឹងបទដ្ឋានផលិតផលចំណីអាហារ ។

គ-គណកម្មាធិការទទួលភារកិច្ចផ្សេងៗទៀត ដែលរដ្ឋាភិបាលបានប្រគល់អោយ ។

**មាត្រា ២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងរដ្ឋមន្ត្រីគ្រប់ក្រសួង ស្ថាប័ន ដែលមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពតាមភារកិច្ច រៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ . ថ្ងៃទី ០៩ ខែ មិនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**ចម ប្រសិទ្ធ**